# សុន្ទរកថារបស់លោក MATSUMOTO Izumi
# លេខាទី២ ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការស្ថានីយផលិតទឹកស្អាតខ្នាតតូច
# ក្នុងឃុំ៦ នៃខេត្តតាកែវ

ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៧

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមគោរព ឯកឧត្តម អ៊ូច ភា អភិបាលរងខេត្តតាកែវ
- សូមគោរព លោក Frédéric Dubois នាយកប្រតិបត្តិអង្គការទឹកស្អាត១០០១
- សូមគោរព ភ្ញៀវកិត្តិយស លោក លោកស្រី

ខ្ញុំមានសេចក្តីសោមនស្សរីករាយណាស់ដែលបានចូលរួមក្នុងពិធីថ្ងៃនេះ ដោយមានវត្តមាន ឯកឧត្តម អ៊ូច ភា អភិបាលរងខេត្តតាកែវដើម្បីអបអរការបញ្ចប់ការសាងសង់ស្ថានីយផលិតទឹកស្អាតខ្នាតតូចក្នុងសាលាបឋមសិក្សាត្រពាំងធំ។

ដោយសារតែការផ្គត់ផ្គង់ទឹកស្អាតជាអាទិភាពមួយនៃជំនួយអភិវឌ្ឍន៍របស់ជប៉ុនសម្រាប់កម្ពុជា គម្រោងជាច្រើនសម្រាប់ការកែលម្អវិស័យផ្គត់ផ្គង់ទឹកស្អាតត្រូវបានអនុវត្តក្រោមជំនួយរបស់រដ្ឋាភិបាលជប៉ុន ដូចជាការសាងសង់ស្ថានីយផលិតទឹកស្អាតខ្នាតតូចក្រោមគម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ ឬជំនួយគូសាណូណិរបស់ជប៉ុននេះផងដែរ។

ស្ថានីយផលិតទឹកស្អាតខ្នាតតូចនេះនឹងធ្វើឲ្យប្រជាជនក្នុងឃុំនេះអាចទទួលបានទឹកស្អាតកាន់តែប្រសើរនិងមានតម្លៃសមរម្យជាងមុន។ ដោយថ្នាក់រៀនគ្រប់ថ្នាក់នៃសាលានេះនឹងទទួលបានទឹកសុទ្ធដោយឥតគិតថ្លៃជារៀងរាល់ថ្ងៃ សិស្សជាង៥៥០នាក់នឹងទទួលបានទឹកស្អាតសម្រាប់ផឹក ហើយស្ថានភាពសុខភាពរបស់ពួកគេនឹងប្រសើរឡើង។

ខ្ញុំសង្ឃឹមថាស្ថានីយផលិតទឹកស្អាតខ្នាតតូចនេះនឹងត្រូវបានថែទាំយ៉ាងល្អ ព្រមទាំងប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពដើម្បីឲ្យប្រជាជនក្នុងតំបន់ក៏ដូចជាសិស្សានុសិស្សក្នុងសាលាបឋមសិក្សានេះអាចបន្តទទួលបានទឹកស្អាតសម្រាប់ផឹកបានយូរអង្វែង។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវអំណរគុណចំពោះលោក-អ្នកទាំងអស់គ្នាដែលបានរួមចំណែកក្នុងការអនុវត្តគម្រោងនេះ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ស្ថានីយផលិតទឹកស្អាតខ្នាតតូចនេះនឹងក្លាយជានិមិត្តរូបនៃមិត្តភាពរវាងប្រទេសយើងទាំងពីរ ហើយព្រមទាំងជួយពង្រឹងបន្ថែមនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនកម្ពុជា និងប្រជាជនជប៉ុន។

សូមអរគុណ!

**Speech by Mr. MATSUMOTO Izumi**
**Second Secretary of the Embassy of Japan in the Kingdom of Cambodia**
**At the Inauguration Ceremony of**
**“the Project for Constructing Water Treatment Kiosks in Six Communes in Takeo Province”**
**14th December 2017**

- Venerable monks,
- His Excellency Mr. Ouch Phea, Deputy Governor of Takeo Province,
- Mr. Frédéric Dubois, Executive Director of Teuk Saat 1001,
- Distinguished guests, ladies and gentlemen,

It is my pleasure to attend today’s inauguration ceremony in the presence of His Excellency Mr. Ouch Phea, Deputy Governor of Takeo Province, to celebrate the completion of the construction of the water treatment kiosk at Trapean Thum Primary School.

As the water supply has been one of the priorities in Japan’s development assistance for Cambodia, various projects for the improvement of water supply have been implemented through Japanese government’s assistance schemes including Grant Assistance for Grassroots Human Security Project, KUSANONE Grant, which supported the construction of this water treatment kiosk.

This kiosk will enable people in this commune to have better and affordable access to safe drinking water. Also, as bottled water will be provided to each class of this school for free every day, safe drinking water for over 550 students is secured and their health condition will also be improved.

I sincerely hope that the water treatment kiosk will be maintained properly and utilized effectively so that the local residents including school children at this primary school can continuously have access to safe drinking water over a long period of time.

Finally, I would like to express my sincere appreciation to all of people who have contributed to the smooth implementation of the project. I strongly hope that this water treatment kiosk will become a symbol of friendship between the two countries and further strengthen friendly relationship between Cambodian and Japanese people.

Thank you very much.